# សុន្ទរកថា

## សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ក្នុងពិធីបិទសន្និបាតផ្សព្វផ្សាយកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល

*(សាលចតុមុខ ថ្ងៃ ពុធ ទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៩)*

---

- *សម្តេច អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោកស្រី និង អស់លោកទាំងអស់*

មកដល់ថ្ងៃនេះអង្គសន្និបាតរបស់យើងបានដំណើរការដល់ ថ្ងៃទី ៤ របស់ខ្លួន ហើយរសៀលថ្ងៃនេះសន្និបាតនឹងត្រូវបញ្ចប់ដោយជោគជ័យ អាស្រ័យដោយអង្គសន្និបាតបានធ្វើការដោយសកម្ម និងទទួលខុសត្រូវខ្ពស់ ។

ជាមួយនឹងការផ្សព្វផ្សាយអំពីកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដែលត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ អង្គសន្និបាតនៅបានយកចិត្តទុកដាក់ឆ្លុះបញ្ចាំងអំពីការ ពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ការបង្កើនប្រសិទ្ធិភាពក្នុងការគ្រប់គ្រង និងការកែទម្រង់សេដ្ឋកិច្ច ហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើអំពីផែនការទូទៅ និងការអភិវឌ្ឍន៍នៃវិស័យកសិកម្ម ការអភិវឌ្ឍន៍ដំណាំកសិកម្ម ឧស្សាហកម្ម ការនាំចេញកសិផល ការជំរុញវិស័យទេសចរណ៍ ការស្វែងយល់អំពី MFN និង GSP ។ល។និង។ល។ អង្គសន្និបាតក៏បានស្តាប់ដោយយកចិត្តទុកដាក់អំពីទស្សនៈរួមនៃក្រសួងបង្កើតថ្មីដូចជាក្រសួងធនធានទឹក និងឧតុនិយម ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងទស្សនៈរួមរបស់ក្រសួងដែល បានការកែសំរួលភារកិច្ច ជាអាទិ៍មានក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គសន្និបាតទាំងមូលដែលមានស្មារតីទទួលខុសត្រូវខ្ពស់ ធ្វើឱ្យសន្និបាតផ្សព្វផ្សាយកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក្លាយទៅជាសន្និបាតនៃការឯកភាពឆន្ទៈ ដើម្បីអនុវត្តនូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។ ខ្ញុំសូមអរគុណជា ពិសេសជូនចំពោះឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង និងឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងមន្ត្រី បុគ្គលិកនៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានដឹកនាំ និងបំរើការ ឱ្យសន្និបាតរហូតដល់ទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ ។

ខ្ញុំសូមអរគុណដល់វាគ្មិនទាំងអស់ដែលបានចូលរួមអធិប្បាយឆ្លុះបញ្ចាំង និងពិភាក្សា ហើយធ្វើឱ្យកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ត្រូវបានអង្គសន្និបាតយល់ជ្រួតជ្រាប ព្រមទាំងត្រៀមខ្លួនជាស្រេចជាមួយនឹងកម្លាំងចិត្ត កាយ និងប្រាជ្ញារបស់ខ្លួន ប្រែក្លាយទៅជាការអនុវត្តន៍ឯកភាព និងព្រមៗគ្នាជាមួយសន្ទុះថ្មីដ៏ខ្លាំងក្លា និងក្នុងចរិតខ្ជាប់ខ្ជួន ។

អង្គសន្និបាតក៏បានដាក់ចេញនូវសេចក្តីសំរេចចិត្តរបស់ខ្លួនដែលឯកឧត្តម សុខ អាន ទើបនឹងបានអានជូនអំបាញ់មិញនេះ ។

- *សម្តេច អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោកស្រី និង អស់លោកទាំងអស់*

បន្ទាប់ពីមានកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីស ស្តីពីសន្តិភាព កម្ពុជា ឆ្នាំ ១៩៩១ និងមានរាជរដ្ឋាភិបាលឆ្នាំ ១៩៩៣ យើងបានរៀបចំឱ្យមានការបោះឆ្នោតសកល សេរីពហុបក្ស គ្មានអំពើហឹង្សា ត្រឹមត្រូវយុត្តិធម៌ និងបានតាមអាណត្តិដែលបានកំណត់នាឆ្នាំ១៩៩៨ ។ ប្រការនេះបានឆ្លុះបញ្ចាំងឱ្យឃើញថា ស្មារតីកម្ពុជាចំពោះការបោះឆ្នោតបានគោរពពេលវេលា អាណត្តិច្បាស់លាស់ ។ ដោយស្មារតីគោរពអាណត្តិនេះហើយដែលវានឹងបង្កើតបានទម្លាប់ដ៏ត្រឹម

ត្រូវនឹងទៀងទាត់សំរាប់លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។ នេះគឺជាសមិទ្ធិផលនយោបាយ សមិទ្ធិផលនៃលទ្ធិប្រជាធិបតេយ្យដ៏ធំធេងមួយដែលកម្ពុជាខ្លួនឯងត្រូវតែបន្តរក្សាឱ្យបានខ្ជាប់ខ្ជួន ។

ផ្តើមពីជោគជ័យនៃការរៀបចំបោះឆ្នោតនាខែ កក្កដា ឆ្នាំ ១៩៩៨ វាក៏នាំឱ្យកើតឡើងបាននូវរដ្ឋាភិបាលមួយស្របតាមឆន្ទៈរបស់ប្រជាជន និងតាមស្មារតីរដ្ឋាភិបាលសេដ្ឋកិច្ចមួយដែលប្រជាជនយើងចង់បាន ។

រដ្ឋាភិបាលសេដ្ឋកិច្ចនេះបានអាយុ២៥ ថ្ងៃ ព្រះរាជាណាចក្រកម្ពុជាយើងបានសំរេចនូវការផ្សះផ្សា និងបង្រួបបង្រួមជាតិ បង្កើតនូវស្ថានភាពមួយ ដែលអស់រយៈកាលដ៏ច្រើនទសវត្សរ៍មកហើយមិនទាន់សំរេចបាន ។ នោះគឺស្ថានភាពកម្ពុជាមួយដែលរដ្ឋាភិបាលបានគ្រប់គ្រងទឹកដីទាំងស្រុង មានសន្តិភាពពេញលេញ ហើយប្រការនេះវាបានទាមទារឱ្យយើងត្រូវថ្នាក់ថ្នម ថែរក្សាដោយប្រុងប្រយ័ត្នដើម្បីឱ្យមានស្ថេរភាពចិរកាលមួយដែលនោះគឺជាមូលដ្ឋានមិនអាចខ្វះបានសំរាប់ធ្វើការកសាងជាតិ និងអភិវឌ្ឍន៍សេដ្ឋកិច្ច ។

និយាយជារួមទៅការផ្សះផ្សា និងបង្រួបបង្រួមជាតិ គឺជាប្រភពនៃសន្តិភាព និងស្ថេរភាព ហើយសន្តិភាព និងស្ថេរភាពនេះ គឺជាកត្តាចាំបាច់មិនអាចខ្វះបាន ដើម្បីឱ្យប្រជាជនកម្ពុជាទាំងអស់បានកសាង និងអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួន ។

មុននឹងខ្ញុំមានយោបល់ជូនអង្គសន្និបាតនូវបញ្ហាមួយចំនួន ជាដំបូងនេះ ខ្ញុំសូមទាញការចាប់អារម្មណ៍អំពីបញ្ហាសិទ្ធិមនុស្ស និងការងារសិទ្ធិមនុស្សរបស់រដ្ឋាភិបាល ។ នេះជាភារកិច្ចអាទិភាពមួយ ក្នុងចំណោមភារកិច្ចជាអាទិភាពទាំងឡាយនៃវិស័យនយោបាយក្នុងប្រទេសរបស់រាជរដ្ឋាភិបាលដែលគប្បីក្នុង ៤ ថ្ងៃនេះ សន្និបាតត្រូវតែមានមូលបទ និងវាគ្មិននិយាយអំពីបញ្ហានេះ ។ នេះមិនមែនមានន័យថា សន្និបាត ៤ ថ្ងៃនេះ មិនមានវាគ្មិន មិនមានមូលបទយកមកពិភាក្សាគ្នាអំពីសិទ្ធិមនុស្សកម្ពុជា ហើយចាត់ទុកថា រាជរដ្ឋាភិបាល យើងមិនយកចិត្តទុកដាក់ដល់បញ្ហាសិទ្ធិមនុស្សនោះទេ ។ ព្រោះថា វាគ្មិនដែលនឹងលើកបញ្ហាសិទ្ធិមនុស្សនៅក្នុងអង្គសន្និបាតនេះ គឺរូបខ្ញុំជានាយករដ្ឋមន្ត្រីតែម្តង ។

សេចក្តីថ្លែងការណ៍ជាសកលអំពីសិទ្ធិមនុស្ស ឆ្នាំ ១៩៤៨ រួមមានទាំងអស់ ៣០ មាត្រា ។ ក្នុងសៀវភៅណែនាំការបង្រៀនអំពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានបង្ហាញនូវករណី ស្តីពីសិទ្ធិជាមូលដ្ឋានរបស់មនុស្សដែលរួមមានចំណុចសំខាន់ៗដូចតទៅ ៖

១. អំពីកិច្ចការពារជីវិតដល់មនុស្សក្នុងសង្គម
២. អំពីសន្តិភាព និងសិទ្ធិដើម្បីមានជីវិត
៣. អំពីអភិវឌ្ឍន៍ និងបរិស្ថាន ៖ ក្នុងចំណុចនេះបាននិយាយដល់បញ្ហាម្ហូបអាហារ ទឹក ផ្ទះសម្បែង ប្រជារាស្ត្រ ការងារ ថាមពល និងសុខភាព
៤. អំពីការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសុខុមាលភាព
៥. អំពីសុខុមាលភាពសង្គម និងវប្បធម៌
៦. អំពីរដ្ឋាភិបាល និងច្បាប់ ដែលក្នុងនោះមាននិយាយអំពីសមភាពចំពោះមុខច្បាប់ អំពីសាលាកាត់ក្តី និងប្រភេទ ផ្សេងៗនៃតុលាការ
៧. សេរីភាពខាងប្រើគំនិត ជំនឿសាសនា សេរីភាពក្នុងការរួមប្រជុំ និងសិទ្ធិរួមចំណែកក្នុងកិច្ចការជាសាធារណៈ
៨. អំពីអង្គការសិទ្ធិមនុស្ស ។

ពិនិត្យលើចំណុចទាំងអស់នេះ ទោះបីយើងមិនបានប្រើពាក្យសិទ្ធិមនុស្ស តែសន្និបាត ៤ ថ្ងៃរបស់យើងបាន ចូលទៅក្នុងមូលបទទាំងនោះស្ទើរតែទាំងអស់ លើកលែងតែអំពីអង្គការសិទ្ធិមនុស្ស ។

ក្នុងសង្គមកម្ពុជាយើង មានអង្គការសិទ្ធិមនុស្សដែលកើតឡើងដោយអង្គការក្រៅរដ្ឋាភិបាល អង្គការសិទ្ធិមនុស្សរបស់រដ្ឋសភា និងអង្គការសិទ្ធិមនុស្សរបស់រាជរដ្ឋាភិបាល គឺគណៈកម្មាធិការសិទ្ធិ មនុស្សកម្ពុជា។ ថ្ងៃខាងមុខ ប្រសិនបើព្រឹទ្ធសភាកើតឡើង ហើយមានគណៈកម្មាធិការសិទ្ធិមនុស្សរបស់ខ្លួនទៀតនោះ យើងនឹងមានមូលដ្ឋាន ព្រាងច្បាប់មួយជូនទៅរដ្ឋសភាស្តីពីសិទ្ធិមនុស្ស និងស្ថាប័នកំពូលមួយរបស់ជាតិដែលរួមគ្នាទទួលខុសត្រូវពីសិទ្ធិមនុស្ស នៅកម្ពុជា ហើយនោះគឺជាស្ថាប័នដែលនឹងបញ្ចូលនូវគ្រប់សមាសភាពនៃអង្គការសិទ្ធិមនុស្សនៅកម្ពុជា ។

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជារបស់រាជរដ្ឋាភិបាល បានព្រាងនូវអត្ថបទច្បាប់ ជាព្រះរាជក្រឹត្យក្តី ឬ អនុក្រឹត្យក្តី ដើម្បីបញ្ជាក់ពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ខ្លួនព្រមទាំងការរៀបចំខ្សែ រយៈចូលទៅក្នុងរដ្ឋបាល ទាំងអស់រាប់ទាំងក្រសួង មន្ទីរ ខេត្ត ក្រុង ស្រុក ឃុំ ភូមិ ទាំងអស់ ។ យើងនឹងជំនះបាននិន្នាការបែងចែក ដោយចាត់ទុកថា រដ្ឋាភិបាលគឺផ្សេង ឯអង្គការសិទ្ធិមនុស្សគឺផ្សេងមួយទៀតដែលជាតួពិតទៅយុទ្ធជនសិទ្ធិមនុស្សដ៏សកម្មបំផុត គឺមន្ត្រីរាជការ នគរបាល កងទ័ពនេះហើយ ដែលបានបំពេញកន្លងមកយ៉ាងច្រើនអំពីការងារសិទ្ធិមនុស្ស។

លើការចាត់តាំងការងារសិទ្ធិមនុស្សនេះ យើងមានគំរូល្អ២ ២ គឺនៅទីស្តីការគណៈរដ្ឋមន្ត្រី មានអនុរដ្ឋ លេខាធិការម្នាក់ទទួល សិទ្ធិមនុស្ស ឯនៅអគ្គសេនាធិការ គឺមានការិយាល័យមួយទទួលបន្ទុកសិទ្ធិមនុស្ស ។ យើងនឹង រៀបចំតាមគ្រប់ក្រសួង និងខេត្ត ក្រុង រហូតដល់តាមភូមិនីមួយ១ ឱ្យមានយ៉ាងតិចយុទ្ធជនស្ម័គ្រចិត្ត ១ នាក់ ដែល បំពេញការងារសិទ្ធិមនុស្ស ។ អ្នកទាំងនោះនឹងមានតួនាទីយ៉ាងសំខាន់ ដើម្បីពិនិត្យមើលស្ថានភាពសិទ្ធិមនុស្សប្រចាំថ្ងៃ និងការបោះឆ្នោតជ្រើសរើសមេឃុំ នាពេលខាងមុខនេះ ។

ពាក់ព័ន្ធទៅនឹងការស្រាវជ្រាវព្រឹត្តិការណ៍បោកគ្រាប់បែកនា ថ្ងៃ ៣០ មីនា ឆ្នាំ ១៩៩៧ នៅមុខរដ្ឋសភា. ករណីឃាតកម្មនាពេលព្រឹត្តិការណ៍ខែ កក្កដា ឆ្នាំ ១៩៩៧ និងករណីផ្សេងទៀតមុនពេលបោះឆ្នោត និងក្រោយបោះ ឆ្នោតឆ្នាំ ១៩៩៨ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា បានធ្វើការស្រាវជ្រាវដោយហ្មត់ចត់ថែមទាំងទាញបាន នូវការសិក្សាមួយចំនួន ដែលប្រការទាំងនេះ នឹងរួមចំណែកយ៉ាងសកម្មដល់ការកែទម្រង់យុត្តិធម៌ នគរបាល រដ្ឋបាល និងកងទ័ព ។

- *សម្តេច អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោកស្រី និង អស់លោកទាំងអស់*

និយាយអំពីសិទ្ធិមនុស្ស គឺត្រូវធ្វើឱ្យបានល្អ នូវការថែរក្សា សន្តិភាព ត្រូវការពារអាយុជីវិតមនុស្សក្នុងសង្គម ត្រូវដោះស្រាយ ម្ហូបអាហារ ទឹក ផ្ទះសម្បែង ប្រជារាស្ត្រ ថាមពល សុខភាព ត្រូវ ពង្រឹងនីតិរដ្ឋ ត្រូវកែទម្រង់ ប្រព័ន្ធយុត្តិធម៌ ត្រូវការពារដល់ការ បញ្ចេញមតិ ត្រូវបង្រួញអំពីគម្លាតរវាងអ្នកមាន និងអ្នកក្រ ។ល។និង ។ល។ អ្នកដែលគួរផ្តល់នូវការសរសើរថា មានស្នាដៃអំពីសិទ្ធិមនុស្ស គួរតែជាអ្នកដែលបានធ្វើការងារទាំងនោះ ជាជាងអ្នក ដែលគ្រាន់តែបានសំដី ។

នេះគឺជាបញ្ហាទី ១ ដែលខ្ញុំចង់ចែករំលែកជូនអង្គសន្និបាត របស់យើង ។

ចូលជ្រៅទៅក្នុងបញ្ហាការងារ រាប់ទាំងការងារយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលផង ខ្ញុំយល់ថា អង្គសន្និបាត បានពិភាក្សា និងជ្រួតជ្រាបយ៉ាងច្រើនមកហើយ ។ ខ្ញុំចង់ជំរាបជូនអង្គសន្និបាតអំពីការជាក់ស្តែងមួយចំនួនដែលត្រូវ យកចិត្តទុកដាក់ ៖

ទី ១ : ត្រូវធ្វើឱ្យរាជរដ្ឋាភិបាលនេះខ្លាំង និងមានប្រសិទ្ធិភាព ។ កន្លងមកទាំងអ្នកវាយតម្លៃអន្តរជាតិ គេបានលើកឡើងថា នាយករដ្ឋមន្ត្រី ហ៊ុន សែន ជាជនខ្លាំង ។ ខ្ញុំដឹកនាំរាជរដ្ឋាភិបាល គឺដឹកនាំ

ថាមពលសរុបរបស់រាជរដ្ឋាភិបាល ហើយខ្ញុំចង់ឱ្យរាជរដ្ឋាភិបាលមួយទាំងមូលខ្លាំង និងមានប្រសិទ្ធិភាព ហើយទាល់តែរាជរដ្ឋាភិបាលនោះ មានជោគជ័យលើបញ្ហា សេដ្ឋកិច្ច និងជីវភាព ទើបអាចហៅថារាជរដ្ឋាភិបាលខ្លាំងមួយទៅបាន ។

ទី ២ : ត្រូវបញ្ឆេះម៉ាស៊ីនអោយដំណើរការព្រមៗគ្នា ខ្លាំងដូចគ្នានៅគ្រប់ក្រសួង មន្ទីរ និងខេត្ត ក្រុង។ គ្មាន ខេត្ត ក្រុង ឬស្រុកណាមួយនៅតំរែតំរក់ដោយមូល ហេតុរង់ចាំនេះ ឬរង់ចាំនោះទេ ។ ខ្ញុំសូមបញ្ជាក់ថា គ្មានករណីរង់ចាំទេ ហើយត្រូវធ្វើការងារឱ្យបានសកម្ម និងទទួលខុសត្រូវខ្ពស់បំផុត នេះហើយគឺជាការទទួលខុសត្រូវមួយ ។ កន្លងមកគេវាយតម្លៃថា នាយករដ្ឋមន្ត្រី ហ៊ុន សែន បានរវៃម៉ាស៊ីនចេញទៅមុខបានឆ្ងាយហើយ គឺការកែទម្រង់ និងវិធានការផ្សេងៗ ដែល ក្រសួងនានារត់តាមមិនទាន់នៅឡើយ។ តំណាក់កាលបន្ទាប់មកគេក៏បានទទួលស្គាល់ថា គណៈរដ្ឋមន្ត្រីទាំងមូលបានប្រឹងរវៃម៉ាស៊ីនស្រុះៗគ្នា នៅទីស្តីការគណៈរដ្ឋមន្ត្រី ហើយឥឡូវនេះ បន្ទាប់ពីសន្និបាតទៅ ខ្ញុំចង់ឱ្យក្រសួងនិមួយៗ ខេត្ត ក្រុង និមួយៗត្រូវតែរវៃម៉ាស៊ីនគ្រប់ៗគ្នា និងធ្វើឱ្យឃើញជាក់ស្តែងនូវការប្រែប្រួលថ្មីរបស់ខ្លួន ។ ក្រសួង និងខេត្ត ក្រុង និមួយៗត្រូវមានកាកែទម្រង់ ឬការកែសំរួលរបៀបរបបការងាររបស់ខ្លួន ពិសេសពាក់ព័ន្ធទៅនឹងទំនាក់ទំនងជាមួយប្រជាជន ភ្ញៀវ អ្នកវិនិយោគ ហើយធ្វើយ៉ាងណាក្នុងរយៈពេលពី១ ទៅ ៣ ខែនេះ ត្រូវតែមានការប្រែប្រួលគួរជាទីពេញចិត្ត មួយដល់សាធារណៈជនទាំងឡាយ ដែលគេមកទាក់ទងការងារ ។ ក្រសួង និងខេត្ត ក្រុងទាំងអស់ មិនត្រូវចាត់ទុកថា ការលំបាករបស់ប្រជាជន ការមកសុំបែបបទធ្វើអាជីវកម្ម ធ្វើវិនិយោគ និងរាល់ការងារទាំងអស់ ជាសាច់ជ្រូកបីជាន់ដែលខ្លួនត្រូវកាប់ចិញ្ច្រាំយកនោះទេ ។ មិនត្រូវឱ្យមានស្ថានភាពទំនាក់ទំនងរវាងក្រសួង ខេត្ត ក្រុង ជាមួយប្រជាជន ភ្ញៀវ និងអ្នកវិនិយោគដែលមានធុរៈ ជាទំនាក់ទំនង ដែលមានជំក្លិនលុយផ្ទាល់ខ្លួននោះឡើយ ។ ខ្ញុំសូមនិយាយម្តងទៀតថា ក្នុងរយៈពេល ១ ខែទៅ ៣ ខែ នេះក្រសួង និង ខេត្ត ក្រុងទាំងអស់ទាំងថ្នាក់ក្រោមរបស់ខ្លួនត្រូវតែមានរបៀបរបបថ្មី ដែលចំណាយពេលតិចតែដោះស្រាយការងារ និងសំណូមពរនានាឱ្យបានច្រើន ហើយត្រូវបានសាធារណៈមតិទទួលស្គាល់ថាខ្លួនមានការបំរើ និងដោះស្រាយប្រកបដោយប្រសិទ្ធិភាព និងភាពត្រឹមត្រូវហើយស្អាតស្អំបំផុត។

ទី ៣ : ពាក់ព័ន្ធនឹងការងារផ្ទៃក្នុង ខ្ញុំសូមទាញការចាប់ អារម្មណ៍មុនបង្អស់ចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលចេញពីក្រសួងនេះទៅ វាមានការ ពាក់ព័ន្ធបញ្ហាដោះស្រាយថវិកាដល់គ្រប់ក្រសួង និង ខេត្ត ក្រុងទាំងអស់របស់រាជរដ្ឋាភិបាល ។ មានករណីកើតឡើង អំពីការកាត់យកភាគរយពីគំរោងថវិកាដែលក្រសួង និងខេត្ត ក្រុងនិមួយៗ ត្រូវមក បើកយកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ប្រការនេះហើយ ខ្ញុំសុំយ៉ាងណាធ្វើឱ្យបាតុភាពនេះត្រូវលុប បំបាត់ជាបន្ទាន់ ហើយមិនបន្តទុកឱ្យក្រសួង និង ខេត្ត ក្រុងទាំងអស់ជួបការលំបាកអំពីបញ្ហានេះទៀត ឡើយ ។ រីឯនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា CDC វិញ ក៏ត្រូវតែពិនិត្យសំរួលរបៀបរបបការងារឱ្យបានយ៉ាងប្រញាប់ផងដែរ ជាពិសេសលុបបំបាត់ករណីយកលុយកាត់ផ្ទាល់ខ្លួន នឹងមិនត្រូវទុកឱ្យសំណើវិនិយោគណាមួយអូសពេលហួស ៤៥ ថ្ងៃនោះទេ ។ បើមានករណីណាមួយចំណាយពេលលើសពី ៤៥ ថ្ងៃ គឺ CDC ត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់។ ចំពោះក្រសួងឯទៀត និងខេត្ត ក្រុងទាំងអស់ ព្រមទាំងថ្នាក់ក្រោមរបស់ខ្លួនក៏ត្រូវធ្វើដូចគ្នានេះដែរ គឺកែលំអរបៀប

របបធ្វើការសំដៅលុបបំបាត់ចោលឱ្យបាន នូវបាតុភាពទារយកលុយកាក់បាតុភាពធ្វើលិខិតស្នាមបញ្ជាក់ដែលមិនត្រឹមត្រូវ និងបាតុភាពផ្សេងៗ ទៀតដែលនាំឱ្យប្រជាជនមានការថ្នាំងថ្នាក់ ។

ទី ៤ : ស្ថាប័ននិមួយៗ រាប់ទាំងក្រសួង និងខេត្ត ក្រុងទាំង អស់ត្រូវយកចិត្តទុកដាក់ស្រាវជ្រាវស្ថិតិទិន្នន័យ ហើយចងក្រងទៅជាមូលដ្ឋានទិន្នន័យសំរាប់ការគ្រប់គ្រង និងវិភាគ ។ ខ្ញុំសូមលើកឧទាហរណ៍ខ្លះៗ ជូនពីទិន្នន័យសាមញ្ញដល់ទិន្នន័យស្មុគស្មាញ ដែលសុទ្ធតែមានផលប្រយោជន៍សំរាប់ការគ្រប់គ្រងការវិភាគ និងការដាក់ចេញនូវផែនការតទៅមុខទៀត។

- ប្រសិនបើយើងចង់ដាក់ភ្លើងខៀវ ក្រហមតាមផ្លូវខ្វែងគ្នាណាមួយយ៉ាងហោចណាស់យើងក៏ត្រូវសិក្សាឱ្យដឹងថា នៅលើផ្លូវនោះតើពេលវេលា ម៉ោងប៉ុន្មាន ថ្ងៃណាខ្លះក្នុងសប្តាហ៍ ដែលមានរថយន្ត និងម៉ូតូឆ្លងកាត់ចំនួនប៉ុន្មានក្នុងមួយម៉ោងៗ ។
- ឧទាហរណ៍មួយទៀត ។ តើមានអ្នកណាដឹងឬទេថា ចំណូលរបស់ស្រីពេស្យាសរុបក្នុងមួយឆ្នាំបានប៉ុន្មាន ? តើចំណូលនេះបានចំណាយទៅលើអ្វីខ្លះ ? ផ្ញើទៅឱ្យឪពុកម្តាយបានប៉ុន្មាន ?
- ឧទាហរណ៍ស្តីពីចំណូលនេះដែរ គឺនៅពេលថ្មីៗនេះ ខ្ញុំបានធ្វើការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ និងកម្មវិធីស្បៀងអាហារពិភពលោក ខ្ញុំបានពិនិត្យដោយយកចិត្តទុកដាក់អំពីចំណូល និងចំណាយរបស់ប្រជាជនយើងតាមតំបន់ខុសៗគ្នា ដូចជាតំបន់ដែលអាចធ្វើស្រូវរាំប់រងការផ្គត់ផ្គង់ខ្លួនឯង តំបន់ដែលខ្វះស្រូវអង្ករប្រមាណ ៣ ខែក្នុងមួយឆ្នាំៗ តំបន់មាត់ទន្លេ តំបន់ចំរុះ ធ្វើស្រែផង ចំការផង តំបន់ដែលប្រជាជនមានអាជីវកម្មក្នុងព្រៃជាដើមយើងឃើញថា សុទ្ធតែមានចំណូលខុសៗគ្នា ហើយចំណាយទៅវិញក៏មានការខុសៗគ្នាដែរ ។

ប្រការនេះខ្ញុំសូមទាញការចាប់អារម្មណ៍អង្គសន្និបាតថា ទោះបីជាត្រូវបំពេញការងារអ្វីក៏ដោយ ការងារតួលេខ ស្ថិតិ និងទិន្នន័យ គឺជាបញ្ហាចម្បងណាស់ ហើយប្រការនេះក្រសួងផែនការ គប្បីជួយដល់គ្រប់ស្ថាប័ន ដើម្បីឱ្យស្ថាប័នទាំងអស់មានជំនាញអំពីបញ្ហានេះ ហើយយកជំនាញនេះធ្វើជាមូលដ្ឋានសិក្សារបស់ខ្លួនឱ្យបានរឹងមាំ ។

ទី ៥ : អំពីការងារនគរបាល និងអាវុធហត្ថ ។ អ្វីដែលអង្គសន្និបាតបានជ្រួតជ្រាបហើយនោះ ខ្ញុំមិននិយាយសារជាថ្មីទេ ប៉ុន្តែខ្ញុំចង់ទាញការចាប់អារម្មណ៍ដល់អង្គសន្និបាតតែលើ ២ ចំណុចតូចប៉ុណ្ណោះ ។

១. គឺអំពីក្របខ័ណ្ឌនគរបាល និងអាវុធហត្ថ បូក បញ្ចូលគ្នាយើងឃើញថា វាមានអត្រាមួយខ្ពស់ណាស់ គឺ ៧ ភាគ ១០០០ មានន័យថា ក្នុង ប្រជាជន ១០០០ នាក់ យើងមាននគរបាល និង អាវុធហត្ថ ៧ នាក់ ឬនគរបាល ១ នាក់ សំរាប់ មនុស្ស ១៤៣ នាក់ ។ នៅប្រទេសដែលមានឧក្រិដ្ឋកម្មធំជាងប្រទេសយើងក៏ដោយក៏គេមានអត្រានគរបាលតែ៣ ភាគ ១០០០ ប៉ុណ្ណោះ ។ នេះជាតួលេខមួយដែលអាចអោយយើងយល់ថា ហេតុអ្វីទើបយើងត្រូវការកាត់បន្ថយក្របខ័ណ្ឌ នគរបាល និងហេតុអ្វីយើងត្រូវការកែទម្រង់ នគរបាលឱ្យមានក្របខ័ណ្ឌសមល្មម និងមានប្រសិទ្ធិភាព ។

២. ពាក់ព័ន្ធ នឹងបញ្ហានគរបាលនេះដែរ គឺជាតុពិតទៅ មាននគរបាលយើងច្រើនណាស់ដែលល្អហើយបំពេញភារកិច្ចដោយស្មោះត្រង់ ព្រមទាំងតស៊ូគ្រប់ការលំបាក រាប់ទាំងក្នុងជីវភាពគ្រួសារផ្ទាល់របស់ខ្លួន ។ ខ្វះការលើកទឹកចិត្តដល់ នគរបាល គឺយើងនឹងធ្វើឱ្យកងកម្លាំងនេះមិនអាចរីកចំរើនទៅបានទេ ។ ថាបញ្ហាជីវភាពប្រាក់បៀវត្សទៅចុះវាជាការលំបាករួម

ដែលមិនអាចដោះស្រាយបានភ្លាមៗនាពេលនេះ ប៉ុន្តែប្រការមួយដែលខ្ញុំយល់ថា យើងអាចធ្វើទៅបាន គឺការរៀបចំឋានន្តរសក្តិដល់មន្ត្រី និងពលនគរបាល ដែលរាប់ឆ្នាំមកនេះអ្នកទាំងនេះគ្មានសក្តិពាក់នឹងគេទេ ។ អ្នកធ្វើល្អត្រូវតម្លើងសក្តិ អ្នកមានកំហុសត្រូវបកសក្តិ ឬបញ្ចុះសក្តិ ចុះបើអ្នកទាំងនេះគ្មានសក្តិពាក់តើមានអ្វីតម្លើង ហើយមានអ្វីសំរាប់បកសក្តិ ឬសំរាប់បញ្ចុះសក្តិទៅនោះ ?

ទី ៦ : អំពីកងទ័ព : ៥ ឆ្នាំកន្លងទៅរាជរដ្ឋាភិបាលកម្ពុជា បានខិតខំយកចិត្តទុកដាក់កសាងកងយោធពលខេមរភូមិន្ទ លើមូលដ្ឋាននៃការរួមបញ្ចូលកម្លាំងប្រដាប់ អាវុធនៃអតីតភាគីអនុវត្តកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឱ្យក្លាយជាកងទ័ពជាតិតែមួយគត់មានភក្តីភាពស្មោះត្រង់ដាច់ខាតចំពោះបុព្វហេតុជាតិ គោរពរដ្ឋធម្មនុញ្ញ មានវិន័យ មានលទ្ធភាព សមត្ថភាពគ្រប់គ្រាន់ ដើម្បីបំពេញភារកិច្ចការពារជាតិ អធិបតេយ្យភាព បូរណភាពដែនដី ថែរក្សា ពង្រឹងសន្តិភាព ស្ថេរភាព សន្តិសុខសណ្តាប់ធ្នាប់សង្គម ទប់ស្កាត់ការវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍ ។

ទោះបីស្ថិតក្នុងស្ថានភាព "អតិផរណា" អំពីចំនួនទ័ពគ្រប់ គ្រង និងក្នុងទ្រង់ទ្រាយ "ក្បាលធំ ខ្លួនតូច ជើងស្គម" និងការលំបាកខ្វះខាតជាច្រើនអំពីការផ្គត់ផ្គង់ជីវភាព គ្រឿងបំពាក់ ប៉ុន្តែកងយោធពលខេមរភូមិន្ទដែលធ្វើសកម្មភាពក្រោមបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ បានពុះពារការលំបាក ឧបសគ្គច្រើនរាប់មិនអស់ ដើម្បីបំពេញភារកិច្ចជូនប្រទេសជាតិ និងប្រជាជនយើងរួមចំណែកយ៉ាងធំធេងក្នុងបុព្វហេតុសន្តិភាព ស្ថេរភាព បង្រួបបង្រួមជាតិ និងការអនុវត្តន៍ប្រជាធិបតេយ្យនៅកម្ពុជា ។

សមិទ្ធិផលលេចធ្លោនៃកងយោធពលខេមរភូមិន្ទ ក្នុងរយៈកាល ៥ ឆ្នាំកន្លងមកនេះ គឺបានរួមចំណែកយ៉ាងធំធេងជាមួយ រាជរដ្ឋាភិបាល ក្នុងការបញ្ចប់ទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹត បើកឡើងនូវទំព័រប្រវត្តិសាស្ត្រថ្មីសំរាប់ប្រជាជាតិកម្ពុជាយើងនេះ គឺការបញ្ចប់សង្គ្រាម ទប់ស្កាត់នូវការវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍ បញ្ចប់នូវតំបន់អបគមន៍ ធ្វើសន្តិភាវូបនីយកម្មតំបន់ដែលខ្មែរក្រហមធ្លាប់កាន់កាប់ដោយខុសច្បាប់ ព្រមទាំងទទួលយកមកវិញនូវកម្លាំងប្រដាប់អាវុធក្រោមការត្រួតត្រារបស់ខ្មែរក្រហមមកធ្វើសមាហរណកម្មក្នុងសង្គមជាតិ ។

ការទទួលយកមកវិញនូវអតីតប្រមុខរដ្ឋ និងអតីតប្រធានរដ្ឋសភាជំនាន់កម្ពុជាប្រជាធិបតេយ្យ មករស់នៅក្នុងសង្គមជាតិជាពលរដ្ឋសាមញ្ញ ជាសញ្ញាគួសសំគាល់យ៉ាងច្បាស់នូវការរលំរលាយរបស់អង្គការចាត់តាំងនយោបាយយោធារបស់ខ្មែរក្រហម ហើយក៏ជាសញ្ញាសំគាល់នូវការឈានដល់ទីបញ្ចប់នៃបញ្ហាខ្មែរក្រហម ដែលប្រៀបដូចជាជម្ងឺរ៉ាំរ៉ៃដ៏កាចសាហាវ និងគ្រោះថ្នាក់មួយដែលកើតឡើងនៅលើទឹកដីកម្ពុជាយើងរយៈកាល ៤០ ឆ្នាំមកនេះ ។

ក្នុងការធ្វើសកម្មភាពបំពេញភារកិច្ច មេបញ្ជាការគ្រប់ជាន់ថ្នាក់ នាយទាហាន នាយទាហានរង ពលទាហាន នៃកងយោធពល ខេមរភូមិន្ទទទួលបានបទពិសោធន៍ដ៏មានតម្លៃយ៉ាងច្រើន ។ បទពិសោធន៍ដែលលេចធ្លោជាងគេ គឺការចេះគួបផ្សំដោយឈ្លាសវៃរវាង វិធានការយោធា និងវិធានការនយោបាយសន្តិវិធីក្នុងការដោះស្រាយសភាពការណ៍ដើម្បីសំរេចនូវភារកិច្ចរបស់ខ្លួន ។ មុននិងរហូតដល់រដូវប្រាំង១៩៩៥-៩៦ សកម្មភាពរបស់កងយោធពលខេមរភូមិន្ទ ផ្តែកលើវិធានការយោធា (ការបើកយុទ្ធនាការសកម្មភាពយោធា) ជាសំខាន់ ។ ប៉ុន្តែក្រោយរដូវប្រាំង ១៩៩៦ ផ្តែកលើបទពិសោធន៍នៅតំបន់ភ្នំវល្លិ៍ និងអនុវត្តតាមនយោបាយឈ្នះ-ឈ្នះ របស់រាជរដ្ឋាភិបាល កងយោធពលខេមរភូមិន្ទដោះស្រាយបានដោយសន្តិវិធីជា បន្តបន្ទាប់សភាពការណ៍នៅតំបន់ប៉ៃលិន ម៉ាឡៃ

សំឡូត រហូតដល់ ចុងក្រោយនេះតំបន់អន្លង់វែង ប្រាសាទព្រះវិហារ នាំមកនូវការឯកភាពទឹកដី និងសន្តិភាពពេញលេញ គ្របដណ្តប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល ។

ក្នុងដំណើរការកែទម្រង់កងទ័ព យើងពុំទាន់សំរេចបាននៅឡើយនូវគោលដៅដែលបានកំណត់ អាស្រ័យដោយកត្តាសញ្ញានុម័តមួយចំនួន សំខាន់ការកើតឡើងនូវព្រឹត្តិការណ៍មិនប្រក្រតីនៅដើម ខែ កក្កដា ១៩៩៧ និងការទទួលធ្វើសមាហរណកម្មកម្លាំងប្រដាប់អាវុធពួកអតីតខ្មែរក្រហមដែលនៅសេសសល់ ។

ការកែទម្រង់មុខតំណែងអគ្គមេបញ្ជាការ អគ្គមេបញ្ជាការរង និងរចនាសម្ព័ន្ធរបស់អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ជាជំហានដ៏សំខាន់ចាំបាច់មួយថ្មី សំដៅរក្សាស្ថេរភាពនយោបាយយូរអង្វែង ជំរុញអញ្ញាក្រឹត្តបនីយកម្មកងយោធពលខេមរភូមិន្ទ ដែលជាឆ្អឹងខ្នងនៃការរក្សាស្ថេរភាព និងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា ។

ការងារបន្តចំពោះមុខ ខ្ញុំបានណែនាំនឹងចេញបទបញ្ជាឱ្យ អនុវត្តនូវការងារមួយចំនួនហើយ នៅក្នុងឱកាសពិធីផ្ទេរ និងប្រគល់តំណែងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ កាលពីថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៩ ។

នៅពេលនេះ ខ្ញុំគ្រាន់តែសូមណែនាំ និងរំលឹកនូវការងារចាំបាច់ចំពោះមុខខ្លះគឺ ៖

១. ចរិតនៃរដ្ឋាភិបាលថ្មីនាអាណត្តិនេះ គឺជារដ្ឋាភិបាលសេដ្ឋកិច្ចប្រជាធិបតេយ្យ ។ ហេតុនេះ ខ្ញុំសូមអំពាវនាវឱ្យនាយទាហាន នាយទាហានរង ពលទាហាន នៃកងយោធពលខេមរភូមិន្ទ រួមទាំងកងរាជអាវុធហត្ថផង ត្រូវជ្រួតជ្រាបឱ្យច្បាស់ ហើយសូមតម្រង់ទិសដៅសកម្ម ភាពឆ្ពោះទៅរកគោលដៅនេះ ដើម្បីជួយឱ្យរដ្ឋាភិបាល សំរេចបានជោគជ័យតាមកម្មវិធីនយោបាយកំណត់ ។

២. បញ្ហាជាចំណុចក្តៅ និងបន្ទាន់នាពេលនេះ គឺត្រូវបោសសំអាតលុបបំបាត់ជាបន្ទាន់នូវអំពើខុសឆ្គងមួយចំនួនរបស់បុគ្គលខ្លះក្នុងកងយោធពលខេមរភូមិន្ទដែលប្រព្រឹត្តល្មើសនឹងច្បាប់ ពាក់ព័ន្ធដល់ការកាប់ព្រៃឈើ ដឹកជញ្ជូនឈើដោយអនាធិបតេយ្យ ការរត់ទំនិញគេចពន្ធដោយ មានជនប្រដាប់អាវុធជាបង្អែក និងអំពើខុសច្បាប់ដទៃទៀតនាំឱ្យប៉ះពាល់ដល់ការរកចំណូលថវិកាជាតិ ។ ត្រូវហ្មឺងម៉ាត់ដាក់វិន័យចំពោះជនគ្រប់រូប ទោះថ្នាក់ណាក៏ដោយដែលប្រព្រឹត្តបទល្មើសទាំងនេះ ហោចណាស់ក៏ត្រូវដកចេញពីកងយោធពលខេមរភូមិន្ទ ដើម្បីកុំអោយគេយកតួនាទីក្នុងកងយោធពលខេមរភូមិន្ទ ទៅប្រព្រឹត្តបទល្មើសនេះតទៅទៀត ។

៣. ត្រូវអនុវត្តឱ្យបានល្អបំផុតនូវការកែទម្រង់ក្នុងកងយោធពលខេមរភូមិន្ទ និងមានផែនការហ្មត់ចត់ក្នុងការកាត់បន្ថយចំនួនទ័ព ៥៥.០០០ នាក់ ក្នុងរយៈពេល ៥ ឆ្នាំ ខាងមុខនេះ ។ ត្រូវក្តាប់ឱ្យជាប់នូវសំណួមពរសំខាន់ និងបន្ទាន់ក្នុងដំណើរការកែទម្រង់នេះគឺ ៖

<u>ទីមួយ</u> : លុបបំបាត់ឱ្យបាននូវចំនួនទ័ពមិនពិតប្រាកដ ដែលខ្ញុំនិយាយថា " ត្រូវបើកយុទ្ធនាការបណ្តេញខ្មោចចេញពីជួរកងទ័ព " ។

<u>ទីពីរ</u> : ទស្សនទាននៃការកាត់បន្ថយកងទ័ព គឺការបង្កើតមុខរបរថ្មីឱ្យអ្នកដែលត្រូវរំសាយឱ្យគេរៀបចំជីវភាពថ្មីបានសមរម្យ ។

៤. រាជរដ្ឋាភិបាលយល់ណាស់ អំពីការលំបាកក្នុងជីវភាពរស់នៅក៏ដូចជាការបំពាក់សំភារៈផ្សេងៗរបស់កងយោធពលខេមរភូមិន្ទ រាជរដ្ឋាភិបាលនឹងខិតខំយកអស់លទ្ធភាពដើម្បីស្វែងរកប្រភពថវិកាដើម្បីដោះស្រាយការលំបាកទាំងនេះ។ ប៉ុន្តែរាជរដ្ឋាភិបាលក៏សូមអំពាវនាវឱ្យនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់នៃកងយោធពលខេមរភូមិន្ទ អនុវត្តតាមតួនាទី ភារកិច្ចរបស់ខ្លួនរួមជាមួយ

រាជរដ្ឋាភិបាល ដើម្បីដោះស្រាយលើកកំពស់ជាបណ្ដើរៗ នូវកំរិតជីវភាពរបស់កងយោធពលខេមរភូមិន្ទ ក៏ដូចជាមន្ត្រីរាជការទូទៅផងដែរសំខាន់គឺត្រូវពង្រីកនូវស្មារតីម្ចាស់ការទទួលខុសត្រូវក្នុងការធានាផ្គត់ផ្គង់ឱ្យបានល្អដល់កម្លាំងរបស់ខ្លួនតាមរបបកំណត់ ជៀសវាងការកឹបកេងបាត់បង់ ខិតខំសន្សំសំចៃ គួបផ្សំនឹងការបង្កបង្កើនផលតាមអង្គភាពនិមួយៗនឹងត្រូសារ ។

ខ្ញុំសូមរំលឹកជូននាយទាហាន នាយទាហានរង ពលទាហាន នៃកងយោធពលខេមរភូមិន្ទ ក៏ដូចជាមន្ត្រីរាជការទាំងអស់ឱ្យជ្រាបថា យើងប្រៀបដូចជាជិះលើទូកតែមួយ យើងនាំគ្នាជួយចូកជួយចែវគ្នាកុំយកជើងរាទឹកនោះយើងនឹងទៅដល់ត្រើយដោយជោគជ័យ ។

ទី ៧ : ពាក់ព័ន្ធទៅនឹងការកែទម្រង់ប្រព័ន្ធយុត្តិធម៌នគរបាល រដ្ឋបាល និងយោធាដែលជាប្រការមួយចាំបាច់វាមានករណីជាច្រើនដែលពាក់ព័ន្ធទៅ នឹងការអនុម័តច្បាប់ បើមិនដូច្នេះទេយើងពុំអាចធ្វើឱ្យប្រែប្រួលបានស៊ីជំរៅអំពីសង្គមរបស់យើងបានឡើយ ។ ជំនាញការសិទ្ធិមនុស្ស អ.ស.ប ក៏បានសិក្សា និងឱ្យមតិយោបល់ដែរថា គ្រាន់តែលើរឿងករណីស្រាវជ្រាវអង្កេតឃាតកម្ម វាក៏បានចោទយ៉ាងច្រើនពីកង្វះខាត នូវច្បាប់ជាមូលដ្ឋានសំរាប់ការងារនេះដូច ជាត្រូវមានច្បាប់ព្រហ្មទ័ណ្ឌថ្មី ត្រូវមានច្បាប់ស្ដីពីនគរបាល ត្រូវមានច្បាប់ស្ដីពីភស្តុតាង ត្រូវមានច្បាប់ស្ដីពីនិតិវិធីអង្កេត ។ល។និង។ល។ ជាមួយគ្នានេះអ្នកជំនាញការទាំងនេះនៅតែសង្ឃឹមថា ចំពោះមុខការរង់ចាំដ៏យូរឱ្យមានការអនុម័តច្បាប់ទាំងនេះ គប្បីរាជរដ្ឋាភិបាលមានឆន្ទៈនយោបាយខ្ពស់ គឺអ្វីដែលរាជរដ្ឋាភិបាលអាចធ្វើទៅបានត្រូវតែខិតខំដោះស្រាយឱ្យបានយ៉ាងសកម្មផងដែរ ។ គណៈរដ្ឋមន្ត្រី នឹងយកចិត្តទុកដាក់ពិនិត្យពិចារណាថែមទៀត អំពីបញ្ហានេះ ។

ទី ៨ : ជាបញ្ហាចុងក្រោយតែជាបញ្ហាសំខាន់ចម្បងជាងគេ គឺបញ្ហាពន្ធដារ ថវិកា បញ្ហាព្រៃឈើ បញ្ហាពុករលួយ បញ្ហាដីធ្លី ។

- កម្ពុជានាថ្ងៃនេះគ្មានពាក្យរួចពន្ធ និងការលើកលែង ពន្ធក្រៅច្បាប់វិនិយោគទៀតទេ ប៉ុន្តែនៅមានបញ្ហារត់ពន្ធ ការឃុបឃិត ពុករលួយក្នុងការប្រមូលពន្ធ ។ ចង់បំបាត់ឱ្យបាននូវការរត់គេចពន្ធ ការបំបាត់ប្រាក់ពន្ធដោយការឃុបឃិត ពុករលួយ ត្រូវចាប់ផ្ដើមពីភាពស្អាតស្អំ និងហ្មត់ចត់ក្នុងមន្ត្រីគយ_រដ្ឋាករ និង ពន្ធដារជាមុន ។ ត្រូវចេះរត់រកលុយចូលថវិកាជាតិ មិនត្រូវទុកឱ្យលុយរត់រកហោប៉ៅមន្ត្រីពុករលួយនោះទេ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវឈានមុខនៅក្នុងការបោសសំអាតអំពើពុករលួយនៅក្នុងក្រ_ សួង ពិសេសផ្នែកគយ-រដ្ឋាករ ពន្ធដារ និងរតនា_ គារ ។ ជាមួយនោះផ្នែកពាក់ព័ន្ធ ពិសេសអាជ្ញាធរដែនដី និង កម្លាំងប្រដាប់អាវុធត្រូវជួយគាំទ្រឱ្យវិស័យហិរញ្ញវត្ថុរកចំណូលជូនជាតិ ។ រាល់ការពាក់ព័ន្ធ និងការរកស៊ីខុសច្បាប់ទាំងអស់ត្រូវបំបាត់ហើយ ត្រូវលើកទឹកចិត្តឱ្យអាជ្ញាធរដែនដី និងកម្លាំងប្រដាប់អាវុធជួយទប់ស្កាត់ ដោយផ្ដល់រង្វាន់លើកទឹកចិត្ត ចំនួន ៥០ ភាគរយ នៃប្រាក់ពិន័យជូនអាជ្ញាធរដែនដី ឬអង្គភាពដែលចាប់បានទំនិញរត់ពន្ធ ។
- រាល់ចំណូលត្រូវបង់ចូលថវិកាជាតិ ឯការចំណាយត្រូវស្ថិតក្នុងច្បាប់អនុញ្ញាត និងត្រូវសន្សំសំចៃ។
- បញ្ហាព្រៃឈើយើងបាននិយាយច្រើនមកហើយ ហើយកំពុងអនុវត្តប្រកបដោយភាពហ្មឹងម៉ាត់ អ្វីដែលខ្ញុំចង់និយាយបន្ថែម គឺមិនត្រូវអនុញ្ញាតឱ្យមានរបស់ដែលហៅថា ប្រមូលឈើចាស់ ដែលជាក់ស្ដែងគេទៅកាប់ឈើថ្មី ។ ប្រសិនមានឈើនៅសល់ពិតមែន គឺត្រូវទុកចោលក្នុងព្រៃនោះ

ទៅចុះមានន័យថា ត្រូវបញ្ចប់ជាស្ថាពរ ។ ត្រូវបន្តយុទ្ធនាការរុករករោងអារឈើ មធ្យោបាយកាប់ឈើនៅក្នុងព្រៃ ដោយរឹបអូស ឬបំផ្លាញចោលដូចយោធភូមិភាគទី ២ បានធ្វើកន្លងមក ។ ត្រូវបញ្ឈប់ការផ្តល់កម្មសិទ្ធិ ឬសិទ្ធិកាន់កាប់លើដីព្រៃរហូតការកំណត់តំបន់ព្រៃ ត្រូវធ្វើរួចរាល់ ។ លើការជាក់ស្តែងអ្នកទៅសុំកាន់កាប់ដីនៅ តំបន់ព្រៃ ច្រើនតែអ្នកមានអំណាច ឬអ្នកមានប្រាក់ នេះជាការបង្កើតឡើងនូវម្ចាស់ដីថ្មី តាមរបៀបព្រៃផ្សៃ បំពានលើដីសាធារណៈផង បំពានលើដីប្រជាជននៅក្បែរនោះផង ដែលជាប្រការមិនអាចអត់ឱនឱ្យបានឡើយ ។

- ភារកិច្ចនៃរាជរដ្ឋាភិបាលអាណត្តិទី ២ នេះ គឺជាភារកិច្ចការពារព្រៃឈើ និងដាំដើមឈើឡើងវិញ យើងត្រូវធ្វើកិច្ចការនេះឱ្យដូចភ្លៀងរលឹម មិនធ្វើមួយឆាវៗដូចភ្លៀងធំ ហើយស្ងាត់ទៅវិញ ដែលនាំដល់ការហិនហោចព្រៃឈើនោះទេ ។
- ចំពោះបញ្ហាដីធ្លី នេះជាបញ្ហាកើតឡើងយ៉ាងស្មុគស្មាញនៅឯមូលដ្ឋាន ។ ការបំពានរបស់អ្នកមានអំណាចលើដីធ្លីរបស់ពលរដ្ឋ ឬដីធ្លីសាធារណៈកើតមានជាហូរហែរដែលចាំបាច់ត្រូវលុបបំបាត់ ។ ក្នុងបញ្ហានេះ ខ្ញុំសុំគូសបញ្ជាក់ជាទ្រឹស្តីថា បើប្រជាជនជាកសិករ ត្រូវមានដីធ្លីធ្វើកសិកម្ម ទើបហៅថាជាកសិករ បើកសិករដើរស៊ីឈ្នួលធ្វើកសិកម្ម គេហៅថា ពលករកសិកម្ម ទ្រឹស្តីនេះខ្ញុំធ្លាប់ប្រើតាំងពីខ្ញុំដឹកនាំកែទម្រង់ដីធ្លីនាពាក់កណ្តាលទសវត្ស ៨០ ដែលនាំដល់ការផ្តល់កម្មសិទ្ធិជូនប្រជាជនលើដីធ្លីហើយខ្ញុំនឹងអនុវត្តតាមទ្រឹស្តីនេះក្នុងអាណត្តិនេះជាបន្តទៀត ។ ដូច្នេះការដោះស្រាយដីធ្លីជាភារកិច្ចរបស់រដ្ឋ គឺប្រជាជនគ្មានដី ត្រូវខិតខំរកវិធីដោះស្រាយដីធ្លីជូនប្រជាជនតាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធ ចាំបាច់ទៅកាន់កន្លែងមានដី ពិសេសដីទំនេរមិនទាន់បានស្តារឡើងវិញ រាប់ទាំងការបំផ្លាញចោលមីនដើម្បីយកដីជូនប្រជាជនបង្កបង្កើនផល។ ប្រជាជនដែលមានដីហើយ ខិតខំរកវិធីដោះស្រាយទឹកដើម្បីបង្កើនរដូវដាំដុះបង្កើនទិន្នផលដើម្បីពង្រីកសមត្ថភាព ចិញ្ចឹមលើផ្ទៃដីដែលមានស្រាប់ ។ ចំពោះប្រជាជនដែលបាន និងកំពុងធ្វើអាជីវកម្មលើដីកសិដ្ឋានរដ្ឋ ដូចជាចំការកៅស៊ូ និងស្រែអំបិល សុំទុកឱ្យគាត់បន្តធ្វើតទៅទៀត ដោយលើកទឹកចិត្តគាត់ ជួយគាត់ឱ្យផលិតអំបិលកាន់តែល្អ លើកទឹកចិត្តគាត់ជួយគាត់ឱ្យដាំកៅស៊ូ ទុកឱ្យគាត់ទទួលផលលើដីធ្លីនេះតកូនតចៅ សំណូមពរតែម៉្យាងគឺកុំឱ្យគាត់លក់ដីធ្លីនេះឱ្យអ្នកផ្សេង ។ វាជារឿងអកុសល ឬជាបញ្ហាគួរឱ្យអស់សំណើច ប្រសិនជាយើងដកដីពីប្រជាជនដែលផលិតអំបិលប្រគល់ឱ្យអ្នកវិនិយោគផលិតអំបិល ដកដីដែលប្រជាជនបានដាំកៅស៊ូ ឬរៀបចំដាំកៅស៊ូ ឱ្យអ្នកវិនិយោគដាំកៅស៊ូ នេះជារបៀបវិនិយោគធ្វើឱ្យប្រជាជនអស់ដី ដែលទីបំផុតប្រជាជននៅ ព្រៃភ្នំ ត្រូវទៅនៅលើកំពូលភ្នំ អ្នកនៅក្បែរទឹក ត្រូវចុះទៅនៅក្នុងទឹក អ្នកនៅក្បែរទីក្រុងរត់ចូល ទីក្រុង ដោយសារការខ្វះដីធ្វើអាជីវកម្ម អំពើរបៀបនេះយើងមិនគ្រាន់តែមិនបានជួយប្រជាជនប៉ុណ្ណោះទេ តែថែមទាំងបំផ្លាញប្រជាជនទៀតផង ។ ពិសោធន៍ល្អមួយដែលគួរសិក្សា គឺគួបផ្សំរវាងការវិនិយោគលើការដាំដុះជាមួយការដោះស្រាយដីធ្លីជូនប្រជាជនដែលឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង ចូលរួមនៅក្រុមហ៊ុនដូងប្រេង ក្នុងខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ គឺក្រុមហ៊ុនជួយសង់ផ្ទះជូនប្រជាជនផ្តល់ដីលំនៅដ្ឋាន និងដីចំការសំរាប់ដាំដូងប្រេង ចំនួន ២ ហិកតា ១ គ្រួសារក្នុងដីសម្បទានដែលលទ្ធផលរបស់វា គឺប្រជាជនក្នុងតំបន់ក្រីក្រក្នុងទីក្រុងភ្នំពេញមានផ្ទះ មានដីដាំដូងប្រេងដែលគាត់ជាម្ចាស់ ឯអ្នកវិនិយោគសំរេចបានការ

ដាំដុះលើដីសម្បទាន ដែលឈានទៅកសាងរោងចក្រផលិតម្សៅប្រេង ដែលនឹងទិញម្សៅប្រេងពីកសិករសំរាប់រោងចក្រ ។ នេះជាបែបផែនកសិ-ឧស្សាហកម្មដែលមិន មែនជាទំនាក់ទំនងរវាងកម្មករជាមួយម្ចាស់រោងចក្រទេ តែជាទំនាក់ទំនងរវាងកសិករផលិតម្សៅប្រេងជា មួយម្ចាស់រោងចក្រដែលត្រូវការទិញម្សៅប្រេងសំរាប់រោងចក្រ ។ ដូច្នេះអ្នកទាំងពីរត្រូវការគ្នាទៅវិញទៅមកផ្តល់ប្រយោជន៍ក៏បានដូចគ្នា ឯរដ្ឋាភិបាលក៏មានផលចំណេញ ព្រោះបានអ្នកវិនិយោគជួយដោះស្រាយដីធ្លីឱ្យប្រជាជនដែលខ្វះដី ។ ចំពោះចំការកៅស៊ូក៏អាចធ្វើដូចនេះបានដែរ ទាំងដីក្នុងកសិដ្ឋាន រដ្ឋ ទាំងដីក្រុមហ៊ុនវិនិយោគ ។

ខ្ញុំសូមអង្វរករចំពោះមន្ត្រីរាជការយើងទាំងអស់មេត្តាបញ្ចប់ការបំពានលើដីធ្លីពលរដ្ឋ ហើយបែរមករកការជួយដោះស្រាយដីធ្លី ជូនប្រជាជនពលរដ្ឋវិញ ។

មុននឹងបញ្ចប់មតិរបស់ខ្ញុំនាពេលនេះ ខ្ញុំចង់ជំរាបជូនអង្គសន្និបាតនូវគន្លឹះមួយដែលគួរយកចិត្តទុកដាក់។ អ្នកជំនាញឯកទេសសេដ្ឋកិច្ច ទោះបីរៀនដល់កំរិតបណ្ឌិត ឬខ្ពស់ជាងនេះទៅទៀតក្តី ឬអ្នកជំនួញដែលមានស្នាដៃក្នុងការរកស៊ីយ៉ាងណាក៏ដោយអត្ថន័យ នៃពាក្យសេដ្ឋកិច្ច ហាក់ដូចជាសង្ខេបមកត្រឹមពាក្យគន្លឹះតែមួយម៉ាត់ទេ គឺជំនឿ ។ ប្រសិនបើគេមានជំនឿ គេហ៊ានដកលុយចេញពីហោប៉ៅមកធ្វើការវិនិយោគ ឬរកស៊ីដែលនោះហើយនឹងបង្កើតឡើងនូវសេដ្ឋកិច្ចនេះឯង ។ ជំនឿគឺជាប្រការសំខាន់ណាស់ ។ ក្នុងវិស័យផ្សេងៗពីនេះក្តី រាប់ទាំងការផ្សះផ្សា និងបង្រួបបង្រួមជាតិក៏ដោយ ក៏សុទ្ធតែត្រូវការគន្លឹះនៃជំនឿនេះផងដែរ ។ គ្មានជំនឿទុកចិត្ត គឺគ្មានអ្វីៗទាំងអស់ ។ ហេតុនេះហើយទើបខ្ញុំសូមជំរាបជូនអង្គសន្និបាត ឱ្យយកចិត្តទុកដាក់ធ្វើឱ្យបានល្អនូវអ្វីៗដែលអាចបង្កើតបាននូវជំនឿដ៏ពិតប្រាកដពីជាតិ និងអន្តរជាតិ មកលើរាជរដ្ឋាភិបាល ហើយតាមរយៈនេះទើបរាជរដ្ឋាភិបាល អាចរកឃើញនូវជោគជ័យក្នុងការកាត់បន្ថយភាពក្រីក្រ បង្កើនជីវភាពរស់នៅរបស់ប្រជាជន បង្កើនប្រាក់បៀវត្សជូនដល់មន្ត្រី បុគ្គលិក រាជការ និងកងកម្លាំងប្រដាប់អាវុធទាំងអស់ទៅបាន ។

អស់លោកបានដឹងហើយថា ប្រជាជនគ្មានប្រាក់បៀវត្សទេ ហេតុនេះការលើកកំពស់ជីវភាពរបស់ប្រជាជនក៏វាមានន័យមិនខុស ពីការតម្លើងប្រាក់បៀវត្សដល់ប្រជាជននោះទេ ។ ការកសាងផ្លូវថ្នល់ស្ពាន ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចផ្សេងៗការបង្កលក្ខណៈងាយស្រួលដល់ការប្រកបមុខរបររបស់គាត់ គឺមានន័យថា បានតម្លើងប្រាក់បៀវត្សដល់ប្រជាជនរបស់យើង ។

ហេតុនេះហើយ ខ្ញុំសូមអង្គសន្និបាតទាំងមូល និងគណៈរដ្ឋមន្ត្រី ព្រមទាំងមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធទាំងអស់សូមរួមគ្នាវេញជាធ្លុងមួយ តស៊ូអំណត់ពុះពារការលំបាកមួយគ្រាដ៏សំខាន់ទៀត ដើម្បីធ្វើអោយកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដែលជាបំណងប្រាថ្នារបស់ប្រជាជនទាំងអស់សំរេចបានជោគជ័យនាពេលខាងមុខ ។ រដ្ឋាភិបាលសេដ្ឋកិច្ច គឺជារដ្ឋាភិបាលសិទ្ធិមនុស្ស ជារដ្ឋាភិបាលនីតិរដ្ឋ ហើយជារដ្ឋាភិបាលដែលយកការកសាង និងលើកស្ទួយជីវភាពរបស់ប្រជាជនជាគោលដៅខ្ពស់បំផុតដែលត្រូវតែសំរេច ឱ្យបាន ។

ខ្ញុំសូមប្រសិទ្ធិពរដ៏បវរមហាជោគជ័យជូនដល់អង្គសន្និបាត ហើយសូមឱ្យអង្គសន្និបាតទាំងមូលទទួលបាននូវពុទ្ធពរទាំង៥ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ និងពរជ័យ ២ ប្រការទៀត គឺ អភិវឌ្ឍនៈ និងសុភមង្គល កុំបីឃ្លៀងឃ្លាតឡើយ ។

*សូមអរគុណ*